00208641

C33/I/4

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៩) |
| **កាលបរិច្ឆេទឯកសារ** | ៖ | ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨ |
| **ភាគីបញ្ជូន** | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម** | ៖ | ភាសាអង់គ្លេស |
| **ប្រភេទឯកសារ** | ៖ | សាធារណៈ |

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា**
**ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការឃុំខ្លួនបណ្តោះអាសន្នដោយមិនជាប់ពាក់ព័ន្ធនឹងការរំលោភលើការឃុំខ្លួនដាច់ដោយឡែកពីគ្នា**

---

**បញ្ជូនដោយ៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក តាន់ សេណារ៉ុង
លោក Anees AHMED

**បញ្ជូនទៅ៖**

**អង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ នួន ជា៖**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE
លោក Andrew IANUZZI
លោក ម៉ម ចាន់ណា

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / July / 2008
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

## ១. សេចក្តីផ្តើម

១. តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដែលស្រដៀងគ្នានឹងអង្គជំនុំជម្រះនេះ កម្រនឹងបំបែកជនជាប់ឃុំឃាំងឲ្យនៅតែម្នាក់ឯងណាស់ដោយសារតែឋានៈរបស់ពួកគេជា សហចុងចោទ[1]។ ការសម្រេចដាក់ឲ្យនៅដាច់ដោយឡែកពីគ្នាណាមួយបែបដូច្នេះ ជាពិសេសនៅក្នុងកាលៈទេសៈទាំងឡាយនៃអង្គភាពមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះនេះ ដែលអ្នកជាប់ឃុំទាំងនោះក៏ជាសហចុងចោទផងដែរនោះ គឺស្មើនឹងការបង្ខាំងឲ្យនៅតែម្នាក់ឯងដោយជាក់ស្តែង (*តាមហេតុ-ការណ៍ជាក់ស្តែង*) ។

២. អង្គបុរេជំនុំជម្រះ ធ្លាប់បានលុបចោលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលស្រដៀងគ្នាចំនួនពីរពីមុនមកហើយ[2] ។ ក្នុងការលុបចោលនោះ អង្គបុរេជំនុំជម្រះ បានលើកសំអាងថា ការកំរិតមិនឲ្យជនជាប់ឃុំឃាំងនានាបានជួបគ្នា គឺដើម្បីការពារផលប្រយោជន៍នៃការស៊ើបអង្កេតបានតាមរបៀបណានោះ គឺមានលក្ខណៈមិនច្បាស់លាស់ទេ ជាពិសេសពេលដែលបទឧក្រិដ្ឋត្រូវបានចោទប្រកាន់ទាំងនោះត្រូវបានប្រព្រឹត្តចំនួន ៣០ ឆ្នាំ កន្លងមកហើយៗ ជនជាប់ឃុំឃាំងទាំងនោះ ក៏ធ្លាប់បានពិភាក្សាគ្នាគ្រប់ពេលវេលាទាំងអស់លើបញ្ហានានា ដែលជាប់ទាក់ទងនឹងការចោទប្រកាន់បែបដូច្នេះ[3] ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដោយគ្មានការប្តឹងឧទ្ធរណ៍ កំពុងតែចងកាតព្វកិច្ចទៅលើសហចៅក្រមស៊ើបអង្កេត ។ ហេតុដូចនេះ សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ដែលកំពុងស្វែងរកការកែ

[1] *ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ករណីរបស់ រដ្ឋអាជ្ញា ទល់នឹង Germain Katanga និង Mathieu Ngudjolo Chui,* សាលដីកាសម្រេចដកហូតគំហាត់ជំនួន និងការប្រាស្រ័យទាក់ទងរវាង Germain Katanga និង Mathieu Ngudjolo Chui, ICC-01/04-01/07, ចៅក្រមតែម្នាក់គត់នៃអង្គបុរេជំនុំជម្រះ ទី-១ ចុះថ្ងៃទី០៣ មីនា ២០០៨ ទំព័រទី ៨ [*ចាប់ពីនេះតទៅហៅថា៖* សាលដីកាសម្រេចលើករណីរបស់ Katanga] ។

[2] *ករណីរបស់ នួន ជា,* ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី២០ ឧសភា ២០០៨ [*ចាប់ពីនេះតទៅហៅថា៖* ដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា] ។

[3] *ករណីរបស់ អៀង សារី,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទ និងប្រពន្ធរបស់គាត់, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៥) ចុះថ្ងៃទី៣០ មេសា ២០០៨ លេខERN 00184951-00184956 A104/II/7 [*ចាប់ពីនេះតទៅហៅថា៖* សេចក្តីសម្រេចស្តីពីសិទ្ធិសួរសុខទុក្ខរបស់ អៀង សារី] ។

00208643

C33/I/4



ប្រែដីកាសម្រេចស្តីពីការដាក់ឲ្យនៅដាច់ដោយឡែកពីគ្នារបស់សហចៅក្រមស៊ើបអង្កេត ដែលបានបំបែកជនជាប់ឃុំនានាឲ្យនៅដាច់ដោយឡែកពីគ្នា តាមរយៈការរារាំងមិនឲ្យមានការប្រាស្រ័យទាក់ទងនៅក្នុងចំណោមពួកគេឡើយ[4] ។ ពួកគេបានកត់សំគាល់ថា ក្នុងខណៈដែលជនជាប់ឃុំ ត្រូវបានចោទប្រកាន់ពីបទរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌ និងសិទ្ធិមនុស្សអន្តរជាតិ ទោះជាយ៉ាងណា វាជាការសំខាន់ដែលតុលាការត្រូវគោរពសិទ្ធិមនុស្សនិងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងធានាឲ្យប្រាកដថាពួកគេទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។

## ២. សាវតានៃអង្គហេតុពាក់ព័ន្ធ

៣. ដោយអនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតែមួយ ដែលមានបទចោទប្រឆាំងនឹងពួកគេដូចៗគ្នា ដែលបច្ចុប្បន្ននេះ ជនត្រូវចោទចំនួនប្រាំរូបកំពុងជាប់នៅក្នុងបន្ទប់ដាច់ដោយឡែកពីគ្នា នៅក្នុងអង្គភាពមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ដែលមានបន្ទប់ (បែបដូច្នោះ) ចំនួនតែប្រាំបី ប៉ុណ្ណោះ ។

៤. ដើមបណ្តឹងឧទ្ធរណ៍រូបនេះ បានឋិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន នៅឯអង្គភាពមន្ទីរឃុំឃាំង ចាប់តាំងពីការនាំខ្លួនរបស់គាត់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧[5] ។ គាត់បានអះអាងថា របបមួយដែលបានហាមឃាត់គាត់មិនឲ្យធ្វើការប្រាស្រ័យទាក់ទងគ្នារវាងរូបគាត់ និងជនជាប់ឃុំឃាំងជាមួយគ្នា គឺមានអនុភាពចំនួន "ជាងដប់ខែ"[6] មកហើយ ។ ការណ៍នេះ បានដកហូត

---

[4] *ករណីរបស់ នួន ជា* បណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងទៅនឹងដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន, សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧/អ.វ.ត.ក-កសចស (អបជ ០៩) ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨ (*ចាប់ពីនេះតទៅហៅថា* បណ្តឹងឧទ្ធរណ៍) ។ មន្ត្រីទទួលបន្ទុកសំណុំរឿងបានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នេះមកសហព្រះរាជអាជ្ញា តាមរយៈអ៊ីម៉េល នៅម៉ោង១០២៧ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ ។

[5] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៤ ។

[6] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៤ ។

មិនឲ្យគាត់ធ្វើការទំនាក់ទំនងជាមួយមនុស្សណាក៏ដោយ នៅក្នុងអង្គភាពមន្ទីរឃុំឃាំង ក្រៅតែពីឆ្មាំគុករបស់គាត់[7] ។

៥. កិច្ចស៊ើបសួរបានចាប់ផ្ដើមនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត ដោយគ្មានបញ្ជាក់ពីមូលហេតុអ្វីទាល់តែសោះ បានជូនដំណឹងទៅសហជនត្រូវចោទ អៀង សារី តាមសំណើរបស់គាត់ថា "ដោយសារកិច្ចស៊ើបសួរកំពុងដំណើរការ" ពួកខ្លួន "មិនមានគំរោងធ្វើការផ្លាស់ប្ដូរណាមួយទេ"នៅក្នុងរបបនៃការហាមឃាត់មិនឲ្យមានការប្រាស្រ័យទាក់ទងគ្នាជាមួយនឹងជនជាប់ឃុំឃាំងនានា[8] ។ ដោយការឈឺចាប់នឹងការបដិសេធសិទ្ធិ (ទាក់ទងគ្នាក្នុង) សង្គមរបស់គាត់ នៅពេលដែលគាត់កំពុងជាប់ក្នុងការឃុំឃាំង (ជាពិសេសសិទ្ធិរបស់គាត់ក្នុងការជួបជាមួយនឹងភរិយារបស់សហជនត្រូវចោទ) អៀង សារី បានប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ជំទាស់ទៅនឹងសេចក្ដីសម្រេច ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ នោះ ។ នៅពេលបានទទួលបណ្ដឹងឧទ្ធរណ៍រួចហើយ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទំនងជា "បើតាមអនុភាពរបស់វា គឺជាដីកាសម្រេចដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា"[9] ។ អង្គបុរេជំនុំជម្រះ បានកត់សម្គាល់បន្ថែមទៀតថា "បើតាមអនុភាពរបស់វា វិធានការចាប់បង្ខំដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតបែបដូច្នេះ អាចមិនមាន ការគោរពសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិទាំងស្រុងទេ"[10] ។

៦. នៅពេលដែលបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ត្រូវបានព្យួរ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានចេញអនុស្សារណៈដោយគ្មានការបញ្ជាក់មូលហេតុមួយទៀត

---

[7] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី ២០ ។

[8] សេចក្ដីសម្រេចស្ដីពីសិទ្ធិសួរសុខទុក្ខ, កថាខណ្ឌទី ២ ។

[9] *ករណីរបស់ អៀង សារី,* សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី អំពីសិទ្ធិសួរសុខទុក្ខ, សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៥) ចុះថ្ងៃទី២១ មីនា ២០០៨ លេខERN 00172265-00172268 A104/II/4 កថាខណ្ឌទី ៦ [*ចាប់ពីនេះតទៅហៅថា៖* សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបានរបស់ អៀង សារី] ។

[10] សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបានរបស់ អៀង សារី, កថាខណ្ឌទី ៩ ។

00208645

C33/I/4



ដោយអនុញ្ញាតឲ្យ អៀង សារី និងភរិយារបស់គាត់ ដែលជាសហជនជាប់ឃុំឃាំង បានជួបគ្នា ម្តងក្នុងមួយសប្តាហ៍ ដោយហេតុថា "កិច្ចស៊ើបសួរមួយចំនួនដែលពីមុនគិតថា ចាំបាច់នោះត្រូវបានបញ្ចប់រួចហើយ"[11] ។

៧. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីសិទ្ធិសួរសុខទុក្ខ ដោយបានសម្រេចថា៖

i. វិធានបានអនុញ្ញាតឲ្យមានការជួបគ្នាដោយមានកំរិតរវាងជនជាប់ឃុំឃាំងនានា ដើម្បីផលប្រយោជន៍នៃការស៊ើបអង្កេត[12] ។ យ៉ាងដូច្នេះក៏ដោយ វិធានការបែបនេះ ត្រូវតែកំរិតតឹងរ៉ឹងបំផុតសំរាប់តែតម្រូវការនៃដំណើរការនិតិវិធី ដោយសមាមាត្រទៅនឹងកំរិតធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និងដោយគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិឲ្យបានពេញលេញ[13] ។

ii. វិធានការបែបនេះ អាចត្រូវចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុ ។ តាមការទាញសំអាងបែបនេះ វាបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់ថាតើវិធានការទាំងនេះផលប្រយោជន៍មួយណាដែលត្រូវការពារ ។ ការកំរិតទៅលើសិទ្ធិណាមួយគួរផ្អែកលើការការពារផលប្រយោជន៍នោះ[14] ។

iii. សហចៅក្រមស៊ើបអង្កេត មិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់ ក្នុងការដាក់ជនជាប់ឃុំឃាំងឲ្យនៅដាច់ដោយឡែកពីគ្នាទេ ហើយមិនបានយកចិត្តទុកដាក់លើ "ផលវិបាក

---

[11] សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបានរបស់ អៀង សារី, កថាខណ្ឌទី ៥ ។

[12] សេចក្តីសម្រេចស្តីពីសិទ្ធិសួរសុខទុក្ខ, កថាខណ្ឌទី ១៥ (លើកឡើងពីវិធាន ៥៥.៥) ។

[13] សេចក្តីសម្រេចស្តីពីសិទ្ធិសួរសុខទុក្ខ, កថាខណ្ឌទី ១៥ (លើកឡើងពីវិធាន ២១.២) ។

[14] សេចក្តីសម្រេចស្តីពីសិទ្ធិសួរសុខទុក្ខ, កថាខណ្ឌទី ១៧ ។

00208646

C33/I/4



ទាំងឡាយ នៃសេចក្ដីសម្រេចរបស់ខ្លួន ដែលបណ្ដាលឲ្យមានការបំបែកគ្នាជាក់ស្ដែងមួយឡើយ”[15] ។

iv. តាមអង្គសេចក្ដីនានា អៀង សារី និងភរិយារបស់គាត់ដែលជាសហជនជាប់ឃុំឃាំង បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាចំនួន ៥៧ឆ្នាំ មកហើយៗ ឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ក៏ត្រូវបានប្រព្រឹត្តចំនួន ៣០ឆ្នាំ កន្លងមកហើយដែរ ។ “ជនត្រូវចោទទាំងឡាយ មានពេលពិភាក្សាគ្នាគ្រប់ពេលវេលាទាំងអស់ លើបញ្ហាណាមួយក៏ដោយដែលពាក់ព័ន្ធនឹងការចោទប្រកាន់នានាបែបដូច្នេះ”[16] ។ នៅក្នុងកាលៈទេសៈបែបនេះ វាមានលក្ខណៈមិនច្បាស់លាស់សម្រាប់អង្គបុរេជំនុំជម្រះអំពីបញ្ហាដែលថាការកំរិតទំនាក់ទំនងរវាងជនជាប់ឃុំឃាំង ផ្ដល់ការការពារដល់ផលប្រយោជន៍នៃកិច្ចស៊ើបសួរយ៉ាងដូម្ដេច[17] ។

v. អំឡុងពេលនៃវិធានការដ៏យូរបែបនេះ “ដែលបានកំណត់តាំងពីកិច្ចស៊ើបសួរចាប់ផ្ដើម [...] ដោយមិនមានការផ្ដល់យុត្តិកម្មសមស្រប បានប៉ះពាល់ដល់សិទ្ធិជនត្រូវចោទក្នុងការទទួលបានការប្រព្រឹត្តិមកលើខ្លួនដោយមនុស្សធម៌ ហេតុដូច្នេះ ត្រូវបញ្ឈប់ជាដាច់ខាត” ។

៨. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការមិនអនុញ្ញាតឲ្យទាក់ទងគ្នាដែលបង្គាប់ដោយសហចៅក្រមស៊ើបអង្កេតនោះ គឺពុំអាចទទួលយកបានឡើយទាំងលក្ខណៈនីតិវិធី និងខ្លឹមសារ ហើយបានច្រានចោលនូវចំណុចនេះ ។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អង្គបុរេជំនុំជម្រះបង្គាប់ថាៈ

---

[15] សេចក្ដីសម្រេចស្ដីពីសិទ្ធិសួរសុខទុក្ខ, កថាខណ្ឌទី ១៨ ។

[16] សេចក្ដីសម្រេចស្ដីពីសិទ្ធិសួរសុខទុក្ខ, កថាខណ្ឌទី ១៩ ។

[17] សេចក្ដីសម្រេចស្ដីពីសិទ្ធិសួរសុខទុក្ខ, កថាខណ្ឌទី ២០ ។

"ជនត្រូវចោទគួរទទួលបានការអនុញ្ញាតឲ្យជួបសួរសុខទុក្ខ អនុលោមតាមវិធាននៃការឃុំខ្លួន ដែលអនុវត្តនៅមន្ទីរឃុំឃាំង អ.វ.ត.ក"[18] ។

៩. ក្នុងកំឡុងពេល២០ថ្ងៃ នៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលហាមមិនឲ្យមានការដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា សហចៅក្រមស៊ើបអង្កេត បានចេញនូវដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា ។ ដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នានេះ បានហាមការជួបគ្នារវាងជនជាប់ឃុំឃាំងដោយមិនច្បាស់លាស់ លើកលែងតែករណីរបស់ អៀង សារី និងភរិយារបស់គាត់ ដែលបង្កើតបានជាប្រភេទមួយដាច់ដោយឡែក ដោយសារអ្នកទាំងពីរបានរៀបការជាប្តីប្រពន្ធនឹងគ្នា[19] ។

១០. ដោយផ្អែកទាំងស្រុងលើសេចក្តីសម្រេច នៃតុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប ("ECHR") និងដោយមិនគិតថាជា"ភាពដាច់ដោយឡែក" ចំពោះយុត្តិសាស្ត្រប្រកបដោយភាពសម្រិតសម្រាំងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា លើកជាទឡ្ហីករណ៍ថា ការបំបែកជនជាប់ឃុំ អាចមានយុត្តិកម្មក្នុងការទប់ស្កាត់ឲ្យមាន "សក្តានុពលណាមួយចំពោះការស៊ីគ្រលំដោយភាពលំអៀង" រវាងគ្នានឹងគ្នា[20]។ ដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នាបានរកឃើញថា ការឃុំខ្លួនបែកពីគ្នាមិនចាំបាច់ ត្រូវការ "ផ្តល់យុត្តិកម្មដោយភស្តុតាងបញ្ជាក់អំពីសកម្មភាពណាមួយជាក់លាក់ទេ" ។ ប៉ុន្តែ "ធាតុផ្សំតែមួយគត់ដែលត្រូវពិចារណា គឺការវាយតម្លៃទៅលើហានិភ័យ"[21] ។ គេទទួលស្គាល់ថា ទោះបីជាការបំបែក មានន័យស្មើនឹងការបំបែកជាក់ស្តែងនៃជនជាប់ឃុំចេញដោយឡែកក្តី ក៏វាពុំបណ្តាលឲ្យមាន ការរំលោភសិទ្ធិជាសារវ័ន្តរបស់ពួកគេដែរ ហើយដោយហេតុនេះ គឺអាចអនុញ្ញាតបាន ។

---

[18] សេចក្តីសម្រេចស្តីពីសិទ្ធិសួរសុខទុក្ខ, កថាខណ្ឌទី ២១ ។

[19] ដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា, កថាខណ្ឌទី ១១ ។

[20] ដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា, កថាខណ្ឌទី ៥ ។

[21] ដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា, កថាខណ្ឌទី ៣ ។

១១. ដោយកើតទុក្ខមិនសុខចិត្តចំពោះដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា ជនត្រូវចោទឈ្មោះ **នួន ជា** ដែលត្រូវបានបំបែកដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា ក៏បានដាក់បណ្ដឹងឧទ្ធរណ៍នេះឡើង[22]។ បណ្ដឹងឧទ្ធរណ៍លើកសំអាងថា ទ្រឹស្ដីនៃករណីយុត្តិសាស្ត្រត្រូវតែយកមកអនុវត្តចំពោះ នីតិវិធីនៅចំពោះមុខតុលាការនេះ និងសន្និដ្ឋាន ដោយអនុលោមតាមសេចក្ដីសម្រេចស្ដីពីសិទ្ធិសួរសុខទុក្ខរបស់អង្គជំនុំជម្រះនេះ របបនៃការដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា មិនមានការចាំបាច់ ហើយក៏គ្មានសមាមាត្រទៅនឹងផលប្រយោជន៍នៃកិច្ចស៊ើបសួរ ។ បណ្ដឹងឧទ្ធរណ៍លើកឡើងថា ករណីយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប បានពឹងផ្អែកទៅលើដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នានេះ គឺមានការពាក់ព័ន្ធគ្នាតិចតួចណាស់ទៅនឹងករណីបែបនេះ កុំថាឡើយនិយាយអំពីការត្រួតត្រា[23] ។

## ៣. ច្បាប់ដែលពាក់ព័ន្ធ

*ទ្រឹស្ដីនៃករណីយុត្តិសាស្ត្រ*

១២. មួយនៅក្នុងចំណោមគោលការណ៍ជាសារវ័ន្ត ដែលកំពុងជួយពង្រឹងដល់ដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ គឺថា ជនណាដែលស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានេះ ហើយដែលត្រូវបានចោទប្រកាន់ពីបទល្មើសដូចគ្នា នឹងត្រូវបានគេប្រព្រឹត្តិមកលើ ស្របទៅតាមវិធាននានាដូចគ្នាដែរ[24] ។ គោលការណ៍នេះ ត្រូវបានបង្ហាញឲ្យឃើញតាមរយៈទ្រឹស្ដីដែលមានការរៀបចំយ៉ាងល្អនៃការប្រកាន់យកតាមអ្វីដែលបានសម្រេច (“ប្រកាន់តាមអ្វីដែលបានសម្រេចពីមុន”) ឬ ហៅយ៉ាងសាមញ្ញថា ទ្រឹស្ដីនៃករណីយុត្តិសាស្ត្រ ។ គោលគំនិតផ្លូវច្បាប់ជាសារវ័ន្តនេះ អាចបែងចែកជាពីរផ្នែក ។ ទីមួយ សេចក្ដីចម្រេចណាមួយរបស់តុលាការជាន់ខ្ពស់ ត្រូវចងទៅលើតុលាការជាន់ទាប ។ ទីពីរ សូម្បីតែតុលាការជាន់ខ្ពស់ ក៏មិនបានច្រានចោលករណីយុត្តិសាស្ត្ររបស់ខ្លួនផ្ទាល់ដោយគ្មានសនិទានភាពដោយបង្ខំនោះដែរ។ ទ្រឹស្ដីនេះធ្វើឲ្យប្រាកដថា តុលាការ

---

[22] វិធាន៧៣.ក ផ្ដល់ការអនុញ្ញាតដល់អង្គបុរេជំនុំជម្រះ នូវ “យុត្តាធិការផ្ដាច់មុខ” ដែលត្រូវមានសមត្ថកិច្ចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ។

[23] បណ្ដឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ៣ ។

[24] វិធាន២១.២.ខ នៃវិធានផ្ទៃក្នុង ។

អនុវត្តទៅតាមសេចក្តីសម្រេចរបស់តុលាការដែលមានពីមុនៗ នៅពេលណាមានចំណុចដែលដូចគ្នាបានកើតឡើងជាថ្មីម្តងទៀត[25] ។

១៣. នៅក្នុងករណី *Aleksovski* តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូកូស្លាវី ("ICTY") បានអះអាងពីសារសំខាន់នៃទ្រឹស្តីនេះ តាមការគូសបញ្ជាក់អំពីភាពចាំបាច់ដើម្បីឲ្យមានភាពស៊ីសង្វាក់គ្នា ស្ថេរភាព និងការព្យាករណ៍នៅក្នុងគោលការណ៍ច្បាប់នានា[26] ។ តុលាការនេះ បានផ្តល់ហេតុផលថា សេចក្តីសម្រេចរបស់តុលាការឧទ្ធរណ៍ កំពុងតែចងទៅលើតុលាការជាន់ទាបដោយសារថាៈ ១) ឋានានុក្រមតុលាការតម្រូវឲ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ត្រូវដោះស្រាយឲ្យបានច្បាស់លាស់ពីបញ្ហាច្បាប់ និងអង្គហេតុ; ២) សារៈសំខាន់នៃភាពជាក់លាក់ និងការព្យាករណ៍នៅក្នុងច្បាប់ព្រហ្មទណ្ឌ និង ៣) ត្រូវគូសបញ្ជាក់អំពីសិទ្ធិនានារបស់ចុងចោទដែលមាន ដូចជាការប្រព្រឹត្តចំពោះករណី ជាដើម[27] ។ ស្រដៀងគ្នានេះដែរ នៅក្នុងករណី *Cossey,* តុលាការសិទ្ធិមនុស្សសហគមអឺរ៉ុប ECHR បានកត់សំគាល់ថា ទោះបីជាមិនបានចង ដោយសេចក្តីសម្រេចមុនៗរបស់ខ្លួនក៏ដោយ ជាធម្មតា គេអនុវត្តតាម និងប្រើប្រាស់សេចក្តីសម្រេចទាំងនោះ ក្នុងន័យផលប្រយោជន៍នៃភាពជាក់លាក់ខាងផ្លូវច្បាប់ និងការអភិវឌ្ឍន៍ច្បាប់ឲ្យមានរបៀបរៀបរយ[28] ។

១៤. មិនដូចគ្នានឹងយុត្តាធិការនៃច្បាប់អង់គ្លូ-អាមេរិក (Common Law) ទេ ទោះបីយុត្តាធិការនៃច្បាប់ស៊ីវិល (Civil Law) មិនប្រកាន់ខ្ជាប់ចំពោះទ្រឹស្តីនៃករណីយុត្តិសាស្ត្រលក៏ដោយ តែ

[25] វចនានុក្រមច្បាប់ Black Law Dictionary ការបោះពុម្ពផ្សាយជាភាសាអង់គ្លេស ឆ្នាំ២០០៤, *Stare Decisis*, ៥៩០ ។

[26] *រដ្ឋអាជ្ញា ទល់នឹង Aleksovski,* សាលក្រមរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ករណីលេខៈ IT-95-14-1-A, ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០, កថាខ័ណ្ឌ ៩៧ (*ចាប់ពេលនេះតទៅហៅថា* សាលាក្រម Aleksovski) ។

[27] សាលាក្រម Aleksovski កថាខ័ណ្ឌទី ១១៣ ។

[28] *ករណី Cossey ទល់នឹង ចក្រភពអង់គ្លេស,* តុលាការសិទ្ធិមនុស្សអឺរ៉ុប, ករណីលេខៈ ១០៨៤៣/៨៤, ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ កថាខ័ណ្ឌទី ៣៥ ។

ការអនុវត្តន៍របស់គេវា គឺមានលក្ខណៈស្រដៀងគ្នាគួរឲ្យកត់សំគាល់[29] ។ នៅក្នុងយុត្តាធិការនៃច្បាប់ស៊ីវិល ស្រដៀងគ្នានឹងកម្ពុជាដែរ តុលាការជាន់ខ្ពស់បំផុតជាទូទៅអនុវត្តទៅតាមសេចក្ដីសម្រេចមុនៗរបស់ពួកគេផ្ទាល់ ហើយតុលាការជាន់ទាបអនុវត្តតាមសេចក្ដីសម្រេចនានារបស់តុលាការជាន់ខ្ពស់[30] ។ ឧទាហរណ៍នៅប្រទេសបារាំង មាននិន្នាការដ៏ខ្លាំងក្លាមួយនៅក្នុងការអនុវត្តន៍តាម ករណីយុត្តិសាស្ត្រ ជាពិសេសចំពោះតុលាការជាន់ខ្ពស់ ។ ជាការពិត *សាលាវិនិច្ឆ័យ* នៅតែ អាចច្រានចោលសេចក្ដីសម្រេចរបស់ខ្លួន ប៉ុន្តែវាមានលក្ខណៈជាក់លាក់ដែលថា គេនឹងមិនធ្វើដូច្នេះឡើយ បើគ្មានហេតុផលផ្សេងៗដ៏មានទម្ងន់នោះ ។ ឥរិយាបថរបស់តុលាការជាន់ទាបចំពោះសេចក្ដីសម្រេចនានារបស់*សាលាវិនិច្ឆ័យ* ជាសារធាតុ គឺមានលក្ខណៈស្រដៀងគ្នាបះបិទទៅនឹងសេចក្ដីសម្រេចរបស់តុលាការជាន់ទាប នៅក្នុងយុត្តាធិការនៃច្បាប់អង់គ្លូ-អាមេរិក ដែលសំដៅទៅរកសេចក្ដីសម្រេចនានារបស់តុលាការជាន់ខ្ពស់[31] ។ នៅក្នុងប្រទេសអ៊ីតាលី ទោះបីសេចក្ដីសម្រេចរបស់សាលាវិនិច្ឆ័យនៃតុលាការកំពូល មិនមែនជាចំណងដ៏តឹងរ៉ឹងក៏ដោយ តែក្នុងការអនុវត្តន៍ ក៏មានតុលាការជាប់ទាបមួយចំនួនតូចដែរ ដែលបានយកលំនាំតាមការបកស្រាយខុសៗគ្នា ។ ជាការសំខាន់ តុលាការនានារបស់ប្រទេសអ៊ីតាលី មិនបានធ្វើសកម្មភាពខុសគ្នាខ្លាំងពេកសំដៅទៅលើសេចក្ដីសម្រេចនានា ដែលគេបានរាយការណ៍ឲ្យដឹង ជាងតុលាការសហរដ្ឋអាមេរិក នោះឡើយ[32] ។

## *ការដាក់ឲ្យជនជាប់ឃុំនៅដាច់ពីគ្នា*

១៥. វិធានផ្ទៃក្នុង ដែលរួមបង្កើតបាននូវក្រមនីតិវិធីដ៏ពេញលេញមួយ បានត្រូវអនុម័តយ៉ាងពិសេសសំរាប់បញ្ញត្តិអំពីដំណើរការនីតិវិធី នៅចំពោះមុខតុលាការ*ពិសេសដែលមានតែមួយនេះ*[33] ។

---

[29] សាលាក្រម Aleksovski កថាខ័ណ្ឌទី ១១៣ ។

[30] សាលាក្រម Aleksovski កថាខ័ណ្ឌទី ៩៣-៩៥ ។

[31] សាលាក្រម Aleksovski កថាខ័ណ្ឌទី ៩៣ ។

[32] សាលាក្រម Aleksovski កថាខ័ណ្ឌទី ៩៤ ។

[33] វិធានផ្ទៃក្នុង បុព្វកថា (ដែលចែងថា: "អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានអនុម័តវិធានផ្ទៃក្នុង ដូចខាងក្រោម ដែលមានគោលបំណងធ្វើការចងក្រងនូវនីតិវិធីជាធរមាន សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក...") ។

វិធានផ្ទៃក្នុងតម្រូវថា លក្ខខណ្ឌនៃការឃុំខ្លួនជនណាម្នាក់ដោយតុលាការនេះ គួរតែធ្វើឡើងដោយគោរពទៅតាមច្បាប់កម្ពុជា វិធានបទដ្ឋានអប្បបរមានៃការឃុំខ្លួនសំរាប់ជនជាប់ឃុំឃាំង និងគោលការណ៍ជាមូលដ្ឋាននៃការប្រព្រឹត្តចំពោះអ្នកទោស របស់អង្គការសហប្រជាជាតិ[34] ។ លើសពីនេះ វិធានទាំងនោះចែងថា មានតែអាជ្ញាធរមានសមត្ថកិច្ចនៃតុលាការនេះប៉ុណ្ណោះ ដែលអាចបង្គាប់ឲ្យមាន "វិធានការចាប់បង្ខំ" និងរំពឹងទុកថា វិធានបែបនេះគួរតែ ១) កម្រិតតឹងរ៉ឹងបំផុត សម្រាប់តែតម្រូវការនៃដំណើរការនីតិវិធី, ២) សមាមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និង ៣) គោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិឲ្យបានពេញលេញ[35] ។

១៦. សេចក្តីព្រាងនៃវិធាននៃការឃុំឃាំងរបស់តុលាការនេះ បានអនុញ្ញាតជាពិសេស នូវការបំបែកឲ្យនៅដាច់ដោយឡែកពីគ្នានៃជនជាប់ឃុំ និងតម្រូវឲ្យអង្គភាពពេទ្យ ពិនិត្យជនជាប់ឃុំ ដែលបានដាក់ឲ្យនៅដាច់ពីគ្នានោះ ជាប្រចាំថ្ងៃ ដើម្បីវាយតម្លៃថាតើ ការបំបែកឲ្យនៅដាច់ពីគ្នានោះគឺ "កំពុងផ្តល់ផលអាក្រក់ណាមួយទៅលើសុខភាពខាងផ្លូវកាយ ឬ ផ្លូវចិត្តរបស់ជនជាប់ឃុំ" ដែរឬទេ[36] ។ វិធានទាំងនោះលុបចោលទាំងស្រុងនូវការបង្ខាំងតែម្នាក់ឯងគត់[37]។ វិធានផ្ទៃក្នុងមានការគិតទៅដល់ការបដិសេធនៃការសួរសុខទុក្ខដោយចាត់ទុកថា ជាវិធានការវិន័យប្រឆាំងនឹងជនជាប់ឃុំ ប៉ុន្តែតម្រូវថា វិធានការបែបនេះអាចនឹងអនុវត្តទៅបានសំរាប់តែរយៈពេលពីរសប្តាហ៍ប៉ុណ្ណោះ ហើយប្រធានអង្គភាពមន្ទីរឃុំឃាំងអាចបង្គាប់ឲ្យមានវិធានការដូច្នេះ បានវៀរលែងតែគេធ្វើឡើងដោយផ្អែកលើការបំពានវិន័យណាមួយ ក្នុងចំណោមវិន័យនានា ដូច

[34] វិធាន១០.៣ នៃវិធានផ្ទៃក្នុង ។

[35] វិធាន២១.២ នៃវិធានផ្ទៃក្នុង ។

[36] វិធានសំរាប់គ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះ ឬប្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ឬឃុំខ្លួនតាមអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (សេចក្តីព្រាងលើកទី១០) វិធានស្តីពីការឃុំខ្លួនរបស់ អ.វ.ត.ក, វិធាន៣(១.២) (*ចាប់ពីនេះតទៅហៅថា* វិធាននៃការឃុំឃាំង) ។

[37] វិធាន១០(២)(២.៥) នៃវិធាននៃការឃុំឃាំង ។

ដែលបានរៀបរាប់ទាំងអស់នោះ[38]។ វិធាននៃការឃុំឃាំងអនុញ្ញាតឲ្យជនជាប់ឃុំ ហៅទូរស័ព្ទចេញក្រៅបាន (ជាសំខាន់ សូម្បីហៅទៅកាន់សហចុងចោទដែលមិនទាន់ចាប់ខ្លួនក៏ដោយ)[39]។

១៧. តុលាការ ICTY[40], តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា("ICTR")[41] និងតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន ("SCSL")[42] បានអនុម័តវិធានផ្សេងៗស្តីពីការឃុំឃាំង ដែលក្នុងចំណោមកិច្ចការផ្សេងៗទៀត បានដាក់បទបញ្ញត្តិអំពីសិទ្ធិក្នុងការប្រាស្រ័យទាក់ទងរបស់ជនជាប់ឃុំ ។ វិធាននៃការឃុំឃាំងរបស់តុលាការ ICTY ដែលបានឆ្លុះបញ្ចាំងលើបញ្ហានេះ ដោយតុលាការ ICTR និង SCSL ចែងថាអយ្យការអាចស្នើឲ្យមានការហាមឃាត់ ឬបទបញ្ញត្តិអំពីការធ្វើទំនាក់ទំនងរវាងជនជាប់ឃុំ ជាមួយតតិយជនណាម្នាក់ដោយសារមូលហេតុផ្សេងៗនាំឲ្យមានការបាត់បង់ប្រយោជន៍ខាងដំណើរការនីតិវិធី ប្រឆាំងនឹងជនជាប់ឃុំ ឬការស៊ើបអង្កេតណាមួយផ្សេងទៀត[43] ។ ស្រដៀងគ្នានេះដែរ ក្រឡាបញ្ជីនៃតុលាការ ICTY ឬមន្ត្រីទទួលបន្ទុកបញ្ជាការនៃអង្គភាពឃុំឃាំងរបស់តុលាការនេះ អាចបដិសេធសិទ្ធិសួរសុខទុក្ខ បើសិន គេមានមូលហេតុសមស្របដែលអាចឲ្យគេជឿបានថា ជនជាប់ឃុំរូបនោះ អាចនឹងកំពុងព្យាយាមជ្រៀតជ្រែកសាក្សីណាម្នាក់ ឬជ្រៀតជ្រែកនៅក្នុងការងាររដ្ឋបាលយុត្តិធម៌[44] ។ ក្នុងខណៈមាន

---

[38] វិធាន១០(៥)(៥.៦), វិធាន១០(៨) នៃវិធាននៃការឃុំឃាំង ។

[39] វិធាន៣០ នៃវិធាននៃការឃុំឃាំង ។

[40] វិធានសំរាប់គ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះ ឬប្តឹងឧទ្ធរណ៍ នៅចំពោះមុខសាលាក្តី ឬឃុំខ្លួនតាមអំណាចរបស់សាលាក្តីនៃ ICTY, ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៥ (*ចាប់ពីនេះតទៅហៅថា* វិធាននៃការឃុំឃាំងរបស់ ICTY) ។ បទបញ្ជាផ្ទៃក្នុងរបស់ ICTY សំរាប់ការបង្កើតនីតិវិធីទទួលពាក្យបណ្តឹងសំរាប់ជនជាប់ឃុំឃាំង, មេសា ១៩៩៥ ។

[41] វិធានសំរាប់គ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះ ឬប្តឹងឧទ្ធរណ៍ នៅចំពោះមុខសាលាក្តី ឬឃុំខ្លួនតាមអំណាចរបស់សាលាក្តីនៃ ICTR, (*ចាប់ពីនេះតទៅហៅថា* វិធាននៃការឃុំឃាំងរបស់ ICTR) ។

[42] វិធានសំរាប់គ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះ ឬប្តឹងឧទ្ធរណ៍ នៅចំពោះមុខតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ឬឃុំខ្លួនតាមអំណាចរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន នៃ ICTY, វិធាន ៤១.ក (*ចាប់ពីនេះតទៅហៅថា* វិធាននៃការឃុំឃាំងរបស់ SCSL) ។

[43] វិធាន៦៤.ក.ii នៃវិធាននៃការឃុំឃាំងរបស់ ICTY, វិធាន៦៤ នៃវិធាននៃការឃុំឃាំងរបស់ ICTR, វិធាន៤៧.ក នៃវិធាននៃការឃុំឃាំងរបស់ SCSL ។

[44] បទបញ្ជាផ្ទៃក្នុងគ្រប់គ្រងលើការត្រួតមើលលើការសួរសុខទុក្ខ និងការប្រាស្រ័យទំនាក់ទំនងជាមួយជនជាប់ឃុំ, អង្គភាពមន្ទីរឃុំឃាំងរបស់ ICTY, ចុះខែមេសា ឆ្នាំ១៩៩៥, វិធាន ៣៣.ក ។

ការហាមឃាត់ការបំបែកដើម្បីធ្វើជាវិធានការវិន័យ វិធាននៃការឃុំឃាំងរបស់តុលាការ ICTY អនុញ្ញាតឱ្យធ្វើបាន *សម្រាប់តែ* ការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ល្អនៅក្នុងមន្ទីរឃុំឃាំង ឬសំរាប់កិច្ចការពារជនជាប់ឃុំ[45] *តែប៉ុណ្ណោះ* ។ វិធានទាំងនោះ គិតទុកជាមុនអំពីការបំបែក "ជនជាប់ឃុំខ្លះ (មិនមែនទាំងអស់ទេ) ពីជនជាប់ឃុំដទៃទៀត" និងថ្លែងថា វិធានបែបនេះត្រូវបានគេធ្វើឡើងតែបន្ទាប់ពីមានការស្វែងរកការណែនាំផ្នែកសុខភាពតែប៉ុណ្ណោះ[46] ។

១៨. នាពេលថ្មីៗនេះនៅក្នុងករណីរឿង *Katanga,* តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") បានធ្វើការស្ទាបស្ទង់អំពីយុត្តិសាស្ត្រដែលពាក់ព័ន្ធ ហើយបានកត់សំគាល់ថា ក្រៅពីឧទាហរណ៍មួយនៅក្នុងករណីរឿង *Delalic,* តុលាការអន្តរជាតិ បានដាក់កម្រិតលើការប្រាស្រ័យទំនាក់ទំនងរបស់ជនជាប់ឃុំ ចំពោះតែ "ពិភពខាងក្រៅ និងមិនរវាងសហជនជាប់ឃុំទេ (ហើយកាន់តែតិចមែនទែន រវាងជនដែលត្រូវបានចោទប្រកាន់រួមគ្នា)"[47] ។ សូម្បីតែការដាក់កម្រិតដូច្នេះក៏ដោយសារតែមាន "ការរំលោភ*ជាក់លាក់ណាមួយ* ទៅលើរបបឃុំឃាំងដែលធ្លាប់កើតមានពីមុនដោយជនជាប់ឃុំ[48] តែប៉ុណ្ណោះ ។ ក្នុងករណី *Delalic,* តុលាការ ICTY បានហាមឃាត់ការប្រាស្រ័យទំនាក់ទំនងដោយមានការលើកលែង រវាងសហចុងចោទដែលជាប់ឃុំ ដោយសារគេ "បានធ្វើការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវការកត់សំគាល់ដោយសម្ងាត់" ក្នុងគោលបំណងដើម្បីជៀងវាងការត្រួតពិនិត្យដោយមន្ត្រីសន្តិសុខ[49] តែប៉ុណ្ណោះ ។

១៩. តាមការអនុវត្តន៍នេះ, ICC បានធ្វើការបែងចែកឱ្យដាច់ពីគ្នារវាងការកម្រិត នៃ*ការប្រាស្រ័យទំនាក់ទំនង* រវាងជនជាប់ឃុំ និងជនទាំងឡាយផ្សេងទៀត[50] និង*ការបំបែកឱ្យ នៅដាច់ពីគ្នា*

[45] វិធាន៤៣ នៃវិធាននៃការឃុំឃាំងរបស់ ICTY ។

[46] វិធាន៤៣ នៃវិធាននៃការឃុំឃាំងរបស់ ICTY ។

[47] សេចក្តីសម្រេច Katanga ទំព័រ១១ ។

[48] សេចក្តីសម្រេច Katanga ទំព័រ១១ ។ មានការបញ្ជាក់បន្ថែម ។

[49] សេចក្តីសម្រេច Katanga ទំព័រ១១ ។

[50] បទបញ្ជាផ្ទៃក្នុងរបស់តុលាការ ICC, បទបញ្ជាផ្ទៃក្នុងលេខ ១០១ ។

នៃជនជាប់ឃុំ ពីសហជនជាប់ឃុំដទៃទៀត[51] ។ គេបានកត់សំគាល់ថា គេអាច បង្គាប់ឲ្យមានការបំបែក*តែក្នុងករណី* (១) ដើម្បីទប់ស្កាត់ជនជាប់ឃុំពីការបង្កើតទំនាស់ជា សក្ខានុពលណាមួយនៅក្នុងមន្ទីរឃុំឃាំង ឬ (២) ដើម្បីជៀសវាងគ្រោះថ្នាក់ផ្សេងៗចំពោះសហជនជាប់ឃុំតែប៉ុណ្ណោះ[52] ។ នៅក្នុងករណីមានការបដិសេធចំពោះការបំបែក គេបានកត់ សំគាល់ថាអយ្យការមិនបានផ្អែកតាមពាក្យសុំរបស់ខ្លួន ទៅលើការរំលោភនៃរបបឃុំឃាំងជាក់លាក់ណាមួយដែលធ្លាប់មានពីមុនទេ ហើយដូចដែលវិធានការដែលបានស្នើឡើងរួមបង្កើតបានជា "ការដាក់កម្រិតដ៏សំខាន់" ទៅលើសិទ្ធិនានារបស់ជនជាប់ឃុំនោះ គេអាចដាក់វិធានបែបនេះបានវៀរលែងតែវិធានការទាំងនោះ បានបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃភាពចាំបាច់ និងសមាមាត្រ-ភាព[53] តែប៉ុណ្ណោះ ។ គេបានពិពណ៌នាអំពីការដាក់កម្រិត "ដើម្បីជាការទប់ស្កាត់" ដែល អយ្យការបានធ្វើនោះ ថាជា "ការស្មានសុទ្ធសាធ" ។ គេបានបន្ថែមទៀតថា នៅក្រោមមាត្រា ៦៧.១ នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម សហចុងចោទមានសិទ្ធិត្រៀមរៀបចំខ្លួនសំរាប់ការពាររបស់គេ និងក្នុងករណីអវត្តមានភស្តុតាងជាក់ស្តែង ដែលគេបាននឹងកំពុងប្រឌិតឡើងអំពីសក្ខីកម្ម ឬភស្តុតាងផ្សេងៗនោះ តុលាការបានគិតថា ការប្រើប្រាស់សិទ្ធិជាសារវ័ន្តនេះអាចធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃនីតិវិធីប្រឆាំងនឹងពួកគេ[54] ។

២០. ក្នុងខណៈដែលអង្គបុរេជំនុំជម្រះ បានពឹងផ្អែកទៅលើករណីរឿង *Katanga* សំរាប់ធ្វើសេចក្តីសម្រេចរបស់ខ្លួនអំពីសិទ្ធិសួរសុខទុក្ខ ដីកាដាក់ឲ្យនៅដោយឡែកពីគ្នាបានពិពណ៌នាថា "វាជាការនៅឯកោ" នៅក្នុងដីកាដាក់ឲ្យនៅដោយឡែកពីគ្នារបស់ពួកគេ[55] ។

## ៤. សេចក្តីអះអាង

*ករណីយុត្តិសាស្ត្រត្រូវតែអនុវត្ត*

[51] បទបញ្ជាផ្ទៃក្នុងរបស់អ្នកកាន់បញ្ជើនៃតុលាការ ICC, បទបញ្ជាផ្ទៃក្នុងលេខ ២០១ ។

[52] សេចក្តីសម្រេច Katanga ទំព័រ ៨ ។

[53] សេចក្តីសម្រេច Katanga ទំព័រ ៩ ។

[54] សេចក្តីសម្រេច Katanga ទំព័រ ១០-១១ ។

[55] សេចក្តីសម្រេចស្តីពីសិទ្ធិសួរសុខទុក្ខ កថាខ័ណ្ឌទី ១១, ដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា កថាខ័ណ្ឌទី ៣ ។

២១. បណ្ដឹងឧទ្ធរណ៍នេះ បានសន្និដ្ឋានថា អនុបាតនៃសេចក្ដីសម្រេចស្ដីពីសិទ្ធិសួរសុខទុក្ខរបស់អង្គបុរេជំនុំជម្រះ ចងកាតព្វកិច្ចចំពោះសហចៅក្រមស៊ើបអង្កេត[56] ។ បណ្ដឹងឧទ្ធរណ៍នោះ បានជំទាស់ថា ដីកាដាក់ឱ្យនៅដាច់ដោយឡែកពីគ្នារបស់សហចៅក្រមស៊ើបអង្កេត បានកម្រិតព្រំដែនចំពោះសេចក្ដីសម្រេចស្ដីពីសិទ្ធិសួរសុខទុក្ខ ចំពោះតែជនជាប់ឃុំឃាំងដែលបានរៀបការហើយតែប៉ុណ្ណោះ ដោយគ្មានយុត្តិកម្ម[57] ឡើយ ។

២២. សហព្រះរាជអាជ្ញាកត់សំគាល់ថា ដីកាសម្រេចអំពីសិទ្ធិសួរសុខទុក្ខ មិនបានសំអាងលើការសម្រេចដែលមានចំពោះសិទ្ធិអាពាហ៍ពិពាហ៍របស់អៀង សារី និងប្រពន្ធរបស់គាត់ឡើយ ប៉ុន្តែបានធ្វើឡើងដោយផ្អែកលើមូលហេតុរបស់ខ្លួន ដោយឈរលើមូលដ្ឋាននៃថេរៈវេលានៃការបែកគ្នាដ៏យូរ ដែលមិនសមហេតុផល ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមានសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិនៃជនជាប់ឃុំ[58] ។ សិទ្ធិមានសេចក្ដីថ្លៃថ្នូរជាមនុស្សជាតិ បានភ្ជាប់មកជាមួយនឹងជនជាប់ឃុំគ្រប់រូប ដោយមិនគិតពីឋានៈនៃអាពាហ៍ពិពាហ៍របស់ជននោះឡើយ ។

២៣. ទោះបីអង្គបុរេជំនុំជម្រះ បានចេញដីកាសម្រេចអំពីសិទ្ធិសួរសុខទុក្ខលើបណ្ដឹងឧទ្ធរណ៍របស់អៀង សារី ក៏ដោយ ក៏គេ បានធ្វើការសម្រេចជាទូទៅមួយថា វិធានការបែបចាប់បង្ខំនៃការឃុំខ្លួន គឺស្មើនឹងការបំបែក ហេតុដូចនេះ ត្រូវបញ្ឈប់ជាដាច់ខាត ។ វិធានការនេះត្រូវបានដាក់ទៅលើគ្រប់ជនជាប់ឃុំទាំងអស់ ហេតុដូច្នេះហើយបានជា អង្គបុរេជំនុំជម្រះបានលៃទុកសំរាប់ជនជាប់ឃុំទាំងអស់ ។ ចរិតទូទៅ និងដែលគ្មានលក្ខណៈជាក់លាក់នៃការរកឃើញរបស់អង្គបុរេជំនុំជម្រះ គឺត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្ដីសម្រេចដែលសរសេរថា: "សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះត្រូវមានអនុភាពដោយអនុញ្ញាតឱ្យជនត្រូវចោទ ជួបគ្នា [...]"[59] ។

### *ការបំបែកឱ្យនៅដាច់ដោយឡែកពីគ្នាមិនមានការចាំបាច់ និងមិនសមាមាត្រទេ*

---

[56] បណ្ដឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ១៥ ។

[57] បណ្ដឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ១៦, ដីកាសម្រេចដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា កថាខ័ណ្ឌទី ១០ ។

[58] សេចក្ដីសម្រេចស្ដីពីសិទ្ធិសួរសុខទុក្ខ កថាខ័ណ្ឌទី ២១ ។

[59] សេចក្ដីសម្រេចស្ដីពីសិទ្ធិសួរសុខទុក្ខ ទំព័រ ៦ ។

២៤. នៅក្នុងបណ្តឹងឧទ្ធរណ៍បានលើកឡើងថា ការបំបែកឲ្យនៅដាច់ដោយឡែកពីគ្នានៅក្នុងមន្ទីរឃុំឃាំងនោះ គឺមិនមានការចាំបាច់ ឬក៏មិនមានសមាមាត្រនោះដែរនៅក្នុងករណីរឿងរបស់ដើមបណ្តឹងឧទ្ធរណ៍[60] ។ បណ្តឹងឧទ្ធរណ៍នោះលើកឡើងតទៅថា ការពោលអះអាងនៅក្នុងដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នានោះថា ធាតុផ្សំតែមួយគត់ដែលត្រូវការចាំបាច់នៅក្នុងដីកាសម្រេចដាក់ឲ្យនៅដាច់ដោយឡែកពីគ្នានោះគឺ "ការវាយតម្លៃអំពីហានិភ័យ" មួយដែលមិនស្របគ្នាជាមួយនិងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលបានតម្រូវថា ការបំបែកឲ្យនៅដាច់ដោយឡែកណាមួយ "ត្រូវតែធ្វើឡើងដោយសេចក្តីសម្រេចមួយដោយមានសំអាងហេតុ"[61] ។

២៥. សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា អនុលោមតាមវិធាន២១.២ វិធានការចាប់បង្ខំណាមួយនៅក្នុងមន្ទីរឃុំឃាំង គួរតែកំរិតឲ្យបានម៉ឺងម៉ាត់ឲ្យមកនៅត្រឹមតែសេចក្តីត្រូវការចាំបាច់របស់ដំណើរការនីតិវិធី សមាមាត្រទៅនឹងទម្ងន់ទោសដែលបានចោទប្រកាន់ ហើយត្រូវតែគារពឲ្យបានពេញលេញចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សតែប៉ុណ្ណោះនោះបានហើយ[62] ។ នៅក្នុងដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នាមិនមានភាពច្បាស់លាស់ទេអំពីថា តើគោលដៅនៃការ "ឃុបឃិតគ្នានៅមុនពេលជំនុំជម្រះក្តីដ៏មានសក្តានុពល"នៅក្នុងចំណោមជនជាប់ឃុំឃាំងនោះមានលក្ខណៈដូចម្តេចនោះ គឺអាចត្រូវបានលើកឡើងដោយការដាក់ឲ្យនៅដាច់ដោយឡែកពីគ្នាតែប៉ុណ្ណោះគត់និងដោយមិនអាចមានមធ្យោបាយផ្សេងៗទៀតដូចជាការការពារសាក្សីនិងជនរងគ្រោះជាដើម..។ល។ នៅក្នុងដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នាក៏មិនបានលើកឡើងផងដែរ អំពីថាតើការឃុបឃិតគ្នានៅមុនពេលជំនុំជម្រះក្តីមិនអាចកើតមានឡើង តាមរយៈមេធាវីរបស់ជនជាប់ឃុំឃាំង សាច់ញាតិនិងអ្នកដទៃទៀតនោះ មានលក្ខណៈដូចម្តេចនោះទេ។

*ច្បាប់ព្រហ្មទណ្ឌអន្តរជាតិគួរតែយកតាមករណីយុត្តិសាស្ត្រ*
*នៃសេចក្តីសម្រេចនានារបស់ ECHR*

[60] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ៣ ។

[61] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ២២, ដីកាសម្រេចស្តីពីសិទ្ធិសួរសុខទុក្ខ កថាខ័ណ្ឌទី ១៧ ។

[62] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ១១, ដីកាសម្រេចស្តីពីសិទ្ធិសួរសុខទុក្ខ កថាខ័ណ្ឌទី ១៥ ។

២៦. ក្នុងបណ្តឹងឧទ្ធរណ៍បានសន្និដ្ឋានថា ដីកាដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា បាននិយាយបំផ្លើសយ៉ាងខ្លាំងអំពីការទាក់ទងគ្នានៃសេចក្តីសម្រេចខ្លះរបស់ ECHR និងអំពី "ការខកខានមិនបានបង្កើតនូវករណីសម្រាប់ធ្វើជាគោលការណ៍" ដោយសារមិនបានពឹងផ្អែកទៅលើករណីយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា ឬដើម្បីចាប់ផ្តើមចេញពីការសាកល្បងលើភស្តុតាង ជាក់ស្តែងដែលគាំទ្រដល់ការសាកល្បងអំពីការវាយតម្លៃអំពីហានិភ័យទេ[63] ។ ក្នុងបណ្តឹងឧទ្ធរណ៍នោះលើកឡើងថា មានសេចក្តីសម្រេចជាច្រើនរបស់ ECHR ដែលបានលើកយកមកសំអាងនៅក្នុងដីកាដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា បានជាប់ទាក់ទងនឹងអង្គការម៉ាហ្វីយ៉ា ឬភេរវកម្មនានា ដែលលក្ខខណ្ឌនៃការឃុំខ្លួនបានដាក់ដើម្បី "កាត់បន្ថយឱ្យបានជាអប្បបរមានូវហានិភ័យដែល [ជនជាប់ឃុំឃាំងនានា] នឹងនៅតែរក្សាទំនាក់ទំនងនឹងគ្នាទៅវិញទៅមកជាមួយអង្គការឧក្រិដ្ឋកម្មទាំងនោះ" [64] ។ បណ្តឹងឧទ្ធរណ៍នោះអះអាងថា ករណីទាំងនេះមិនអាចយកមកអនុវត្តនៅទីនេះបានទេ ។ ខ្មែរក្រហមលែងមានតទៅទៀតហើយជាង១០ឆ្នាំមកនេះ "គ្មាននរណាម្នាក់អាចអះអាងដែលគួរឱ្យជឿទុកចិត្តបានថា ការប៉ុនប៉ងណាមួយក្នុងការដោះលែង [ជនជាប់ឃុំឃាំង] ដោយវិធីសាស្ត្រហឹង្សា ធ្លាប់ត្រូវបានគេគិតគូរតាំងពីមុនមកហើយនោះទេ"[65] ។

២៧. សហព្រះរាជអាជ្ញាកត់សំគាល់ថា ភាគច្រើននៃករណីរឿងរបស់ ECHR ដែលត្រូវបានលើកមកសំអាងនៅក្នុង ដីកាដាក់ឱ្យនៅដាច់ដោយពីគ្នា ដែលក្នុងនោះរួមមានករណីទាំងឡាយដែលបានលើកយកមកសំអាង ដើម្បីធ្វើយុត្តិកម្មចំពោះការបំបែកឱ្យនៅដាច់ដោយឡែកពីគ្នា ដែលទាក់ទងតែទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន*ដោយផ្ទាល់ (per se)* ។ ឧទ្ធរណ៍ ដីកាដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា បានពឹងផ្អែកជាសំខាន់បំផុតទៅលើករណីរឿងក្តីរបស់ *Bak* ដើម្បីធ្វើយុត្តិកម្មចំពោះការបំបែកជនជាប់ឃុំឃាំង ឱ្យនៅដាច់ដោយឡែកពីគ្នា ។ នៅក្នុងសេចក្តីសម្រេចនោះបានសម្រេចអំពី *រយៈពេលនៃការឃុំខ្លួន* វែងជាងនេះ (តែមិនមែនអំពី ការបំបែក

[63] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ៣, ២២-៧ ។

[64] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ២៨, ដីកាសម្រេចដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា លេខយោងជើងទំព័រ៩ (ដែលយោងករណី *Messina* កថាខ័ណ្ឌ៦៦) ។

[65] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ២៨ ។

ឲ្យនៅដាច់ដោយឡែកពីគ្នានោះទេ) "ដែលអាចមានសារៈសំខាន់ដើម្បី [ទប់ស្កាត់កុំឲ្យជនជាប់ឃុំឃាំង] គេចខ្លួនបាត់ បំផ្លាញភស្តុតាង និង [... ] កុំឲ្យប្រើឥទ្ធិពល ឬគម្រាមកំហែងសាក្សីនានា"[66] ។

២៨. ដើម្បីប្រើប្រាស់សេចក្តីសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្ននានា នៅក្នុងការធ្វើសេចក្តីសម្រេចលើការបំបែកឲ្យនៅដាច់ដោយឡែកពីគ្នានេះ គឺបានភ្ជាប់គ្នានូវទស្សនទានផ្នែកច្បាប់ដែលខុសៗពីគ្នាចំនួន២ ។ ដីកាដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា ហាក់ដូចជាបានរួមបញ្ចូលគ្នានូវទស្សនទានទាំងពីរនេះ ដោយសារតែទស្សនាទានទាំងនេះហាក់ដូចជាបំរើឲ្យគោលដៅនៃគោលការណ៍ស្រដៀងគ្នា។ ទោះបីជាយ៉ាងនេះក៏ដោយ ការខុសគ្នាយ៉ាងខ្លាំងគឺជាកម្រិតមួយ។ ការបំបែកឲ្យនៅដោយឡែកពីគ្នា គឺជាវិធានការដ៏តឹងរឹងបំផុតមួយ។ យុត្តាធិការរបស់ ECHR និងសេចក្តីសម្រេចរបស់តុលាការ ICC នៅក្នុងករណីរឿងក្តីរបស់ *Katanga* បង្ហាញឲ្យឃើញថា និន្នាការដើម្បីធ្វើយុត្តិកម្មចំពោះការបំបែកឲ្យនៅដាច់ដោយឡែកពីគ្នាគឺមានលក្ខណៈខ្ពស់ជាងកំរិតនៃការធ្វើយុត្តិកម្មចំពោះការឃុំខ្លួនបណ្តោះអាសន្នឆ្ងាយណាស់ ។ ជាញឹកញាប់ការធ្វើយុត្តិកម្មចំពោះការឃុំខ្លួនបណ្តោះអាសន្នតែងតែមានអត្ថិភាព ដោយមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃកម្រិតក្នុងការបំបែកឲ្យនៅដាច់ដោយឡែកពីគ្នានោះទេ។ ទោះបីជាអាចមានបញ្ហាស្តីពីគោលការណ៍នោះក្តី ក៏ការសម្រេចទាំងពីរនោះមានការលេចចេញនូវការពិចារណា និងអង្គហេតុដែលខុសពីគ្នា ។ ហេតុដូចនេះហើយបានជាកាលពីថ្ងៃ១៣ ខែមីនា ឆ្នាំ២០០៨ តុលាការ ICC បានសម្រេចថា ខ្លួននឹងមិនអនុញ្ញាតឲ្យមានការបំបែកជនជាប់ឃុំឃាំងណាម្នាក់ឲ្យនៅដាច់ដោយឡែកពីគ្នាទេ ក៏ប៉ុន្តែនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ តុលាការនេះនៅតែសម្រេចថា ការឃុំខ្លួននេះគឺជាការត្រឹមត្រូវ ។

២៩. សហព្រះរាជអាជ្ញា យល់ឃើញថា ការពឹងផ្អែកទៅលើយុត្តិសាស្ត្រដែលមានលក្ខណៈខុសគ្នាផ្នែកអង្គហេតុរបស់ ECHR ដែលជាអង្គការតំបន់សំរាប់ដោះស្រាយបទឧក្រិដ្ឋក្នុងស្រុក ដោយ

[66] ដីកាសម្រេចដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា លេខយោងជើងទំព័រ១ (ដែលយោងករណី *Bak* កថាខ័ណ្ឌទី ៥៦) ។

ធ្វើមិនដឹងមិនឮចំពោះយុត្តិសាស្ត្រ ដែលផ្តល់អំណោយផលយ៉ាងសំខាន់ចំពោះជនជាប់ឃុំឃាំង ដែលមានមកពីតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដូចជា ICTY និង ICC ដែលមានលក្ខណៈស្រដៀងគ្នានឹងតុលាការនេះដែរ ហើយដែលទទួលដោះស្រាយលើករណីរឿងក្តីដែលធ្ងន់ធ្ងរដូចគ្នាដែរនោះ គឺជាការមិនត្រឹមត្រូវទេ ។ នៅក្នុងករណីណាក៏ដោយ បើមានភាពមិនប្រាកដប្រជា ឬ ភាពមិនស៊ីសង្វាក់គ្នាណាមួយនៅក្នុងច្បាប់ជាធរមាន គួរតែបានដោះស្រាយក្នុងន័យបំពេញតាមបំណងរបស់ជនជាប់ឃុំ[67] ។

## ៤. សេចក្តីសន្និដ្ឋាន

៣០. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គបុរេជំនុំជម្រះ យល់ព្រមទទួលនូវបណ្តឹងឧទ្ធរណ៍នេះ និងធ្វើសេចក្តីសម្រេចលើបណ្តឹងនេះដោយផ្អែកតាមការសម្រេចពីមុន នៅក្នុងសេចក្តីសម្រេចស្តីពីសិទ្ធិជួបសួរសុខទុក្ខរបស់ អៀង សារី ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨
**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** **លោក** Robert PETIT

[67] ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ, មាត្រា២២(២) ។